ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

# តាងនាមប្រជារាស្ត្រខ្មែរ
## តុលាការកំពូល

សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៤៩
ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០

សាលដីកា
លេខ: ២៣
ចុះថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣ ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជំរះដូចខាងក្រោម:

១-ឯកឧត្តម [redacted] ជាប្រធាន
២-លោក [redacted] ជាចៅក្រម
៣-លោក [redacted] ជាចៅក្រម
៤-លោក [redacted] ជាចៅក្រម
៥-លោក [redacted] ជាចៅក្រម

ក្រឡាបញ្ជី
លោក [redacted]

តំណាងមហាអយ្យការ
លោក [redacted] ព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខពីសាលដីកាព្រហ្មទណ្ឌលេខ៧៣ស ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ១៤៩ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ របស់តុលាការកំពូល។

ពីបទ: បង្ករបួសស្នាមដោយចេតនា និងបរិហារកេរ្តិ៍ ប្រព្រឹត្តនៅភូមិនិងឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤១ និងមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

១-ជនជាប់ចោទឈ្មោះ [redacted] ម្ចាស់បណ្តឹងសាទុក្ខ ភេទស្រី អាយុ២៥ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម មុខរបរមេផ្ទះ ឪពុកឈ្មោះ [redacted] ម្តាយឈ្មោះ [redacted] ប្តីឈ្មោះ [redacted] មានកូន ទោសពីមុនគ្មាន។

ពីបទ: បង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិនិងឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។



Scanned by CamScanner

40/4

២-ជនជាប់ចោទឈ្មោះ[redacted]-ជាចុងបណ្ដឹងសាទុក្ខ- ភេទស្រី អាយុ៣៤ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្នភូមិបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម មុខរបរលក់ដូរ ឪពុកឈ្មោះ [redacted]-ស- ម្ដាយឈ្មោះ[redacted]-ស- ប្ដីឈ្មោះ[redacted]-រ- មានកូន០១នាក់ ទោសពីមុនគ្មាន។

-កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ វេលាម៉ោង៦ល្ងាច ឈ្មោះ[redacted]បានចុះពីលើផ្ទះទៅមុជទឹក ហើយឃើញឈ្មោះ[redacted]ដែលមានកំពុងហាលសម្លៀកបំពាក់។ ពេលនោះ[redacted]នសម្ដីឯមុខឈ្មោះ[redacted]ហើយបានធ្វើជាស្រែកឲ្យដីដូនឈ្មោះ [redacted] ឈ្មោះ[redacted]បានស្រែកតបមកវិញថា មីស្មេញ ឈ្មោះ[redacted]បានស្រែកឲ្យវិញថា មីផិតប្ដី រួចក៏យកដុំថ្ម គប់គ្នាទៅវិញទៅមកបណ្ដាលឲ្យមានរបួសរៀងខ្លួន។

-បានឃើញសេចក្ដីសន្និដ្ឋានរបស់តំណាងអយ្យការអមសាលាដំបូងខេត្តកំពង់ចាមថា៖

-ចោទប្រកាន់ឈ្មោះ[redacted]អាយុ២៥ឆ្នាំ ភេទស្រី ជាតិខ្មែរ នៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ពីបទៈបរិហាកេរ្តិ៍ និងបង្ករបួសស្នាមដោយចេតនា បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា៤១ និង៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ចោទប្រកាន់ឈ្មោះ[redacted]អាយុ៣៤ឆ្នាំ ភេទស្រី ជាតិខ្មែរ នៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម ពីបទៈបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ បទល្មើសដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៤៣-គ- ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ដែលបានសម្រេច៖

១-ផ្ដន្ទាទោសលើឈ្មោះ[redacted]ភេទស្រី អាយុ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០៦ខែ(ប្រាំមួយខែ) តែទោសនេះត្រូវព្យួររយៈពេលសាកល្បងចំនួន០៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះចូលជាស្ថាពរ ពីបទៈបង្ករបួសស្នាមដោយចេតនា និងបរិហាកេរ្តិ៍ ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ តាមមាត្រា៤១.៦៣ និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

-ផ្ដន្ទាទោសឈ្មោះ[redacted]ភេទស្រី អាយុ៣៤ឆ្នាំ ដាក់ពន្ធនាគារកំណត់ ០២ខែ -ពីរខែ- តែទោសនេះត្រូវព្យួររយៈពេលសាកល្បង០៥ឆ្នាំ គិតពីថ្ងៃ សាលក្រមនេះចូលស្ថាពរពីបទៈបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ តាមមាត្រា៤១ និង៧០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-បង្គាប់ឲ្យឈ្មោះ [redacted]សងសំណងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តចំនួន ៣.០០០.០០០រៀល (បីលានរៀលគត់) ទៅឲ្យដើមបណ្ដឹងរដ្ឋប្បវេណីឈ្មោះ[redacted]និងឲ្យឈ្មោះ [redacted]សងសំណងថ្លៃថ្នាំព្យាបាល និងជម្ងឺចិត្តចំនួន១.០០០.០០០រៀល (មួយ

Scanned by CamScanner

40/3

លាទរៀលគត់) ទៅឲ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ការប្តឹងទាមទារលើសពីនេះលើកចោល ក្នុងករណីឈ្មោះ [redacted] មិនព្រមសងប្រាក់ជនទណ្ឌនោះទេ អនុញ្ញាតឲ្យចាប់ដាក់គុកបង្ខំលើរូបកាយតាមមាត្រា៧ នៃច្បាប់ស្តីពីការដាក់គុកបង្ខំលើរូបកាយក្នុងរឿងព្រហ្មទណ្ឌ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈប្រកាសចំពោះមុខជនល្មើស និងត្រូវជាដើមបណ្តឹងរដ្ឋប្បវេណី សម្រេចបើកផ្លូវឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ៦៦ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ២៣-គ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់ សាលាដំបូងខេត្តកំពង់ចាម ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថាៈ

១-មានពិរុទ្ធភាព និងកស្តុតាងដាក់បន្ទុកលើឈ្មោះ [redacted] ពីបទៈបរិហាកេរ្តិ៍ និងឈ្មោះ [redacted] ពីបទៈបង្ករបួសស្នាមដោយចេតនា ប្រព្រឹត្តនៅភូមិបុសខ្នុរ ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម កាលពីថ្ងៃទី២៥ ខែមេសា ឆ្នាំ២០០៥ តាមមាត្រា៤១ និង៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

២-សំអាងហេតុនៃសេចក្តីសម្រេចនៃសាលក្រមលេខ២៣"គ" ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់តុលាការខេត្តកំពង់ចាម មានលក្ខណៈត្រឹមត្រូវតម្កល់ទុកជាបានការ។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ៧៣-ស ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចៈ

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់ឈ្មោះ [redacted] ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយខាសគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ២៣-គ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០០៦ របស់សាលាដំបូងខេត្តកំពង់ចាម ទុកជាបានការទាំងមូល។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ចំពោះមុខជនជាប់ចោទ និងមេធាវីការពារជនជាប់ចោទ បើកសិទ្ធិប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ១៩៨ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ប្តឹងមិនសុខចិត្តនឹងសាលដីកាព្រហ្មទណ្ឌលេខ៧៣-ស ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញលិខិតបង្គាប់ឲ្យឈ្មោះ [redacted] ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ធ្វើសារណាការពារ ប៉ុន្តែឈ្មោះនេះពុំបានធ្វើសារណាដាក់ជូនតុលាការកំពូល តាមកំណត់ឡើយ។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការតុលាការកំពូលថាៈ

Scanned by CamScanner

40/2

-ទទួលបណ្ដឹងសាទុក្ខលេខ១៩៨ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់និងគតិច្បាប់។

-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ៧៣"ស" ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-បានស្ដាប់ប្រធានសួរសារតាជាតិ និងចម្លើយអះអាងរបស់ជនជាប់ចោទឈ្មោះ [redacted] នាពេលសវនាការថាៈថ្ងៃកើតហេតុនាងខ្ញុំចុះពីលើផ្ទះទៅមុជទឹក ឃើញឈ្មោះ [redacted] ដែលកំពុងហាលសម្លៀកបំពាក់គ្រាន់តែមើលមុខគេ គេស្រែកដាក់ខ្ញុំថាមីស្វេញ នាងខ្ញុំក៏បានស្រែកវិញថាមីផិតប្ដី រួចឈ្មោះ [redacted] បានយកដំបងគប់មកលើនាងខ្ញុំក៏មានរឿងកើតឡើង។

សំណូមពរៈរកយុត្តិធម៌ឲ្យនាងខ្ញុំផង។

-ក្រោយពីបានស្ដាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្ដាប់ចម្លើយរបស់ម្ចាស់បណ្ដឹងសាទុក្ខ

-ក្រោយពីបានស្ដាប់សេចក្ដីសន្និដ្ឋានរបស់មេធាវីការពារជនត្រូវចោទ

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

**<u>តុលាការកំពូល</u>**

-យល់ឃើញថា បណ្ដឹងសាទុក្ខលេខ១៩៨ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ឈ្មោះ [redacted] ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្ដីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្ដី និងមាត្រា៤៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

-យល់ឃើញថា ការដែលសាលាដំបូងខេត្តកំពង់ចាម និងសាលាឧទ្ធរណ៍សម្រេចផ្ដន្ទាទោសលើឈ្មោះ [redacted] ពីបទៈបង្ករបួសស្នាមដោយចេតនា លើឈ្មោះ ទុយ ចាន់ទូច កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ប្រព្រឹត្តនៅភូមិ-ឃុំបុសខ្នុរ ស្រុកចំការលើ ខេត្តកំពង់ចាម តាមមាត្រា៤១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល នោះជាការត្រឹមត្រូវហើយពីព្រោះ ចម្លើយរបស់ជនត្រូវចោទបានធ្វើយទទួលស្គាល់ថាបានបង្ករបួសស្នាមទៅវិញទៅមក ហើយការទទួលស្គាល់នេះស្របនឹងចម្លើយរបស់ឈ្មោះ [redacted] លទ្ធផលកោសល្យវិច័យលើឈ្មោះ [redacted] ប ខ១១/២០០៦ ចុះថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០០៦ របស់មន្ទីរពេទ្យបង្អែកខេត្តកំពង់ចាម និងចម្លើយសាក្សីឈ្មោះ [redacted] ដែលការនេះបញ្ជាក់អំពីពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ពីបទៈបង្ករបួសស្នាមដោយចេតនា។

-យល់ឃើញថា ជនត្រូវចោទឈ្មោះ [redacted] ទបរិហាកេរ្ដិ៍ លើឈ្មោះ [redacted] ដោយនិយាយថា "មីផិតប្ដី" ដែលអំពើនេះជាបទបរិហាកេរ្ដិ៍បទល្មើសព្រហ្មទណ្ឌដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

Scanned by CamScanner

-យល់ឃើញថា តាមមាត្រា៦៣ថ្មី នៃច្បាប់ស្តីពីវិសោធនកម្មមាត្រា៦៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល និងមាត្រា នៃក្រមនីតិវិធីព្រហ្មទណ្ឌទណ្ឌកម្មមានលក្ខណៈជាពិន័យ ពេលផ្សារ ស្រាលជាងទោសតុកៗ ដូចនេះតម្រូវតុលាការកំពូលអនុវត្តតាមមាត្រា១០ នៃក្រមព្រហ្មទណ្ឌ។

-យល់ឃើញថា សំណងរដ្ឋប្បវេណីដែលសាលាដំបូង និងសាលាឧទ្ធរណ៍សម្រេចបង្គាប់ឲ្យឈ្មោះ [redacted]សងចំនួន៣លានរៀល មានលក្ខណៈសមស្របតាមព្យសនកម្មនៃអំពើល្មើសហើយ។

-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ៧៣"ស" ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមក នេះមានលក្ខណៈត្រឹមត្រូវតាមគតិច្បាប់ លើកលែងតែទណ្ឌកម្ម ដែលសម្រេចលើឈ្មោះ [redacted]ដែលត្រូវញែកឲ្យដាច់ពីគ្នាលើបទបង្ករបួសស្នាម និងបរិហាកេរ្តិ៍។

**ហេតុដូច្នេះ**

**· វិនិច្ឆ័យសេចក្តី**

១-ទទួលផ្នែកខ្លះ និងបដិសេធផ្នែកខ្លះ នៃបណ្តឹងសាទុក្ខលេខ១៩៨ ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់ឈ្មោះ[redacted]

២-តម្កល់សាលដីកាសភាព្រហ្មទណ្ឌលេខ៧៣"ស" ចុះថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការលើកលែងតែទណ្ឌកម្មលើឈ្មោ[redacted]ត្រូវបដិសេធចោល។

៣-បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ១៤៩ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០១០ របស់តុលាការកំពូលទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញលើចំណុចទណ្ឌកម្មលើឈ្មោះ [redacted]

៤-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៨ ខែមករា ឆ្នាំ២០១៣។

| ប្រធាន | ចៅក្រម | ចៅក្រម | ចៅក្រម | ចៅក្រម | ក្រឡាបញ្ជី |
|---|---|---|---|---|---|
| [redacted] | [redacted] | [redacted] | [redacted] | [redacted] | [redacted] |

បានចម្លងចេញពីសាលដីកាដើមត្រឹមត្រូវហើយ។
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៣
ក្រឡាបញ្ជី
[redacted]

បានឃើញ
រាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៣
ប្រធានតុលាការកំពូល
[redacted]